# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សិក្ខាសាលាផ្សព្វផ្សាយតាមអនឡាញស្តីពី "ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)"

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២




© ប្រភពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០ នាទី ព្រឹក ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ (Zoom) ស្តីពី **"ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)"** ក្រោមអធិបតីភាពឯកឧត្តម **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ** ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពន្ធដារពាក់ព័ន្ធ ព្រមទាំងវត្តមានរបស់លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី និងនាងកញ្ញា ជាអភិបាល ឬតំណាងសហគ្រាសចំនួន ៥៦០នាក់។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង

បញ្ញាបចំណេះដឹងដល់អ្នកជាប់ពន្ធ ពាក់ព័ន្ធនឹងការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ខាងមុខនេះ និងជាពិសេសដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដែលរាជរដ្ឋាភិបាលមានគោលនយោបាយមិនបង្កើនអត្រាពន្ធឬបង្កើតពន្ធថ្មី ដោយត្រូវពង្រឹង ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលមានស្រាប់ និងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យអស់សក្តានុពល។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋាពន្ធដារបាននឹងកំពុងរៀបចំអភិវឌ្ឍប្រព័ន្ធដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធ E-Filing ពាក់ព័ន្ធនឹងការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធអនុវត្តឱ្យមានតម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងគោលដៅប្រមូលចំណូលពន្ធឱ្យបានគ្រប់និងលើសផែនការដែលកំណត់ដោយច្បាប់។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អេង រតនា** មានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានចូលរួមដ៏ច្រើនក្នុងអង្គសិក្ខាសាលានេះ ដែលបញ្ជាក់ឱ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការឈ្វេងយល់អំពីកាតព្វកិច្ចអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជ-កម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) បន្ទាប់ពីអគ្គ-នាយកដ្ឋានពន្ធដារបានដាក់ចេញនូវសេចក្តីណែនាំលេខ២០៥២២ អពដ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបកស្រាយលម្អិតជូនអ្នកជាប់ពន្ធក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់ខ្លួន ស្របតាមខ្លឹមសារប្រកាសលេខ ៥៤២ សហវ.ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ព្រមទាំងមាត្រា៧៥ នៃច្បាប់ស្តីពីសារពើពន្ធ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាពន្ធដារសម្រាប់ដាក់ឱ្យអ្នកជាប់ពន្ធអនុវត្តជាបន្តបន្ទាប់ដូចជា Tol E-Filing, E-Filing, E-Payment, GDT Tax Pre-filing App និងប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Document Submission System) ព្រមទាំងការស្នើសុំវិញ្ញាបនបត្រ/លិខិតអនុញ្ញាតនានាតាមប្រព័ន្ធអនឡាញ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ កាត់បន្ថយពេលវេលា និងស្របតាមរបត់នៃបច្ចេកវិទ្យាសម័យទំនើបនាពេលបច្ចុប្បន្ននេះ។

តាមរយៈសិក្ខាសាលានេះ លោក **សុង កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បានធ្វើបទបង្ហាញពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ជូនដល់អ្នកជាប់ពន្ធបានយ៉ាងក្បោះក្បាយ។

ជាកិច្ចបញ្ចប់ ឯកឧត្តម **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ព្រមទាំងជូនពរលោកឧកញ៉ា លោកជំទាវ លោក-លោកស្រី និងសិក្ខាកាមទាំងអស់ ជួបតែវិបុលសុខ សមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

កម្មវិធីសិក្ខាសាលានេះ បានបញ្ចប់នៅវេលាម៉ោង ១២:០០ នាទីថ្ងៃត្រង់ ថ្ងៃដដែល ដោយទទួលបានលទ្ធផលជាផ្លែផ្កាក្រោមស្មារតីកិច្ចសហប្រតិបត្តិការ និងការទទួលខុសត្រូវខ្ពស់៕




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ